សាលាសាធារណៈភតឡ្វេន

7

# សេចក្ដីណែនាំ អំពីការសិក្សា សម្រាប់គ្រួសារសិស្សសាលា

សេចក្ដីសង្ខេបអំពីអ្វីខ្លះ ក្មេងៗ គួរដឹង គួរធ្វើ និងមធ្យោបាយនានា សម្រាប់គ្រួសារទាំងឡាយ បង្កើនការរៀនសូត្រនៅតាមគេហដ្ឋានរៀងៗខ្លួន ។



ថ្នាក់ទី 7

## អំពីមគ្គុទេសក៍សិក្សាទាំងនេះ៖

មគ្គុទេសក៍ការសិក្សានេះតំណាងឲ្យបញ្ហាសំខាន់បំផុតមួយចំនួនដែលកូនលោកអ្នកគួរដឹង ហើយអាចធ្វើនៅដំណាច់ឆ្នាំសិក្សាក្នុងមុខវិជ្ជាសិល្បៈភាសាអង់គ្លេស និងគណិតវិទ្យា។ គោលដៅសិក្សាជួយឲ្យក្រុមគ្រួសារ និងលោកគ្រូអ្នកគ្រូដឹងថាតើពេលណាសិស្សអាចត្រូវការការគាំទ្របន្ថែម និងថាតើពេលណាពួកគេត្រូវការពុះពារវិតតែច្រើនជាងនេះ។

## តើគ្រួសារអាចធ្វើអ្វីខ្លះ?

មានកិច្ចការជាច្រើនដែលលោកអ្នកអាចធ្វើដើម្បីគាំទ្រការសិក្សាកូនលោកអ្នក និងជួយរៀបចំអនាគតរបស់ពួកគេ។ ទាំងអស់នេះគឺជាកត្តាមួយចំនួនដែលនឹងជួយសិស្សឱ្យសិក្សា៖

1. ណែនាំកូនឲ្យយល់ថា ការសិក្សាមានសារៈសំខាន់ចំពោះលោកអ្នក។ ប្រាប់ពួកគេពីបញ្ហាការអប់រំថាវាគឺជាមូលដ្ឋានសម្រាប់ភាពជោគជ័យ។
2. ផ្តល់អាទិភាពដល់សាលារៀន ធ្វើឱ្យប្រាកដថា កូនលោកអ្នកទៅសាលារៀនទាន់ម៉ោងជារៀងរាល់ថ្ងៃ។
3. សហការជាមួយសាលារៀន និងបង្ហាញនូវការគោរពចំពោះលោកគ្រូអ្នកគ្រូ និងបុគ្គលិក។
4. លើកទឹកចិត្តភាពម្ចាស់ការ ទុកឲ្យកូនលោកអ្នកបង្កើតកំហុស និងទទួលខុសត្រូវចំពោះជម្រើសរបស់ពួកគេ។
5. និយាយជាមួយកូនលោកអ្នកអំពីអ្វីដែលកំពុងកើតមាននៅក្នុងសាលារៀន។
6. និយាយជាមួយលោកគ្រូអ្នកគ្រូរបស់កូនលោកអ្នក ដើម្បីធ្វើឲ្យប្រាកដថា កូនលោកអ្នកកំពុងមានវឌ្ឍនភាពពេញមួយឆ្នាំ។
7. ចូលរួមសន្និសីទរវាងលោកគ្រូអ្នកគ្រូ និងឪពុកម្តាយ និងព្រឹត្តិការណ៍សាលារៀនផ្សេងទៀតនៅពេលក៏ដោយដែលអាចទៅរួច។
8. លោកអ្នកមានសិទ្ធិដឹងថាតើកូនលោកអ្នកកំពុងរៀនសូត្រយ៉ាងដូចម្តេច សូមកុំរារែកក្នុងការទាក់ទងលោកគ្រូអ្នកគ្រូរបស់ពួកគេ ប្រសិនបើលោកអ្នកមានចម្ងល់។

## ការពិភាក្សាជាមួយលោកគ្រូអ្នកគ្រូរបស់កូនលោកអ្នក

វាមានសារៈសំខាន់ក្នុងការពិភាក្សាជាមួយលោកគ្រូអ្នកគ្រូ និងសាលារៀនឲ្យបានទៀងទាត់អំពីវឌ្ឍនភាពរបស់កូនលោកអ្នកឆ្ពោះទៅរកគោលដៅសិក្សា។ ទាំងនេះគឺជាសំណួរ ឬប្រធានបទមួយចំនួនដែលលោកអ្នកអាចចង់ពិភាក្សា៖

- ពិនិត្យឡើងវិញនូវមគ្គុទេសក៍សិក្សា ហើយសាកសួរពីមុខវិជ្ជាដែលកូនលោកអ្នករៀនពូកែ និងមុខវិជ្ជាដែលចាំបាច់ត្រូវពង្រឹងបន្ថែម។
- បន្ថែមលើគោលដៅសិក្សានៅក្នុងមគ្គុទេសក៍នេះ តើមានគោលដៅដទៃទៀតដែលកូនលោកអ្នករំពឹងថានឹងសម្រេចបានដែរទេ?
- ស្នើសុំមើលគំរូកិច្ចការរបស់កូនលោកអ្នក និងរបៀបដែលពួកគេបំពេញបានតាម ឬមិនបំពេញបានតាមគោលដៅសិក្សា។
- សាកសួរពីរបៀបដែលវឌ្ឍនភាពរបស់កូនលោកអ្នកត្រូវបានវាយតម្លៃពេញមួយឆ្នាំសិក្សា។
- សាកសួរថាតើកូនលោកអ្នកនឹងឆ្លើយតបតាមគោលដៅសិក្សាតាមកម្រិតថ្នាក់ដែរឬទេ។ ប្រសិនបើមិនឆ្លើយតបទេ តើសាលារៀននឹងផ្តល់ការគាំទ្រអ្វីខ្លះ? តើលោកអ្នកអាចធ្វើអ្វីខ្លះដើម្បីជួយកូននៅផ្ទះ?

- សាកសួរថាតើកូនលោកអ្នកស្ថិតនៅក្នុង ឬលើសពីកម្រិតរំពឹងទុកនៃការសិក្សាដែរឬទេ។ ប្រសិនបើដូច្នេះ តើសាលារៀននឹងផ្តល់ការគាំទ្រអ្វីខ្លះទៀត? តើខ្ញុំអាចធ្វើអ្វីខ្លះនៅផ្ទះ?

## ការពិភាក្សាជាមួយកូនលោកអ្នក

"តើការរៀនសូត្រនៅថ្ងៃនេះយ៉ាងម៉េចដែរ?"
"ល្អតើ"
"តើកូនបានធ្វើអ្វីខ្លះ?"
"មិនធ្វើអ្វីនោះទេ"

តើចំណុចនេះស្តាប់ទៅទំនងទេ? មិនថ្មីទេ សូមសួរតទៅទៀត! សិស្សដែលឪពុកម្តាយចូលចិត្តពិភាក្សាជាមួយអំពីការរៀនសូត្រ តែងតែរៀនសូត្របានល្អប្រសើរនៅសាលារៀន។ ទាំងនេះគឺជាវិធីមួយ ចំនួនដែលលោកអ្នកអាចឲ្យកូនចូលរួម និងគាំទ្រភាពជោគជ័យរបស់ពួកគេ។

- ឆ្លៀតពេលពិភាក្សាជាមួយកូនពីកិច្ចការសាលាជារៀងរាល់ថ្ងៃ។
- ឲ្យកូនលោកអ្នកប្រាប់ពីអ្វីមួយដែលគេបានរៀននៅថ្ងៃនេះ។ តើអ្វីដែលកូនលោកអ្នកគិតថាជារឿងដែលគួរឲ្យចាប់អារម្មណ៍បំផុត? តើអ្វីហាក់ដូចជាពិបាក?
- ពិនិត្យឡើងវិញនូវក្រដាសកិច្ចការ និងគម្រោងដែលកូនលោកអ្នកយកមកពីសាលា។ ឲ្យកូនលោកអ្នកប្រាប់ពីអ្វីដែលបានរៀន និងពន្យល់បកស្រាយ។
- លើកសរសើរកូនចំពោះការខិតខំប្រឹងប្រែងរៀនសូនត្រ ដោយមិនគ្រាន់តែនិយាយថា "ចម្លើយត្រឹមត្រូវហើយ" តែប៉ុណ្ណោះទេ។
- សួរកូនលោកអ្នកអំពីអ្វីដែលគេកំពុងគិត៖ តើកូនឯងដឹងតាមរបៀបណា? តើកូនគិតយ៉ាងម៉េចដែរ? តើកូនឯងកត់សម្គាល់ឃើញអ្វីខ្លះ? ហេតុអ្វីបានជាកូនធ្វើវាតាមវិធីនោះ? តើមានវិធីផ្សេងទៀតសម្រាប់ស្វែងរកចម្លើយទេ?

## ការគាំទ្រការសិក្សាក្រៅពីសាលារៀន

ការរៀនសូត្រមិនមែនឈប់ត្រឹមពេលសិស្សចាកចេញពីសាលារៀននោះទេ។ សិស្សចំណាយពេលវេលានៅក្រៅសាលារៀនច្រើនជាងនៅក្នុងសាលារៀន។ ទាំងនេះគឺជាវិធីមួយចំនួនដែលលោកអ្នកអាចជួយគាំទ្រការសិក្សាខាងក្រៅសាលារៀន៖

- ជំរុញឲ្យកូនអានសៀវភៅ អានជាមួយកូនលោក និងលើកកម្ពស់អំណានក្នុងគ្រួសារ – តាមភាសាដែលលោកអ្នកចេះច្រើនបំផុត។
- រៀបចំទីកន្លែងមួយដែលស្ងប់ស្ងាត់ និងមានផាសុកភាពសម្រាប់កូនធ្វើលំហាត់ ឬធ្វើសកម្មភាពសិក្សាដទៃទៀត។
- ព្យាយាមបង្កើតកាលវិភាគទៀងទាត់សម្រាប់ធ្វើលំហាត់ ឬសកម្មភាពសិក្សាដទៃទៀត។
- ប្រើមគ្គុទេសក៍នេះដើម្បីផ្តោតលើគោលដៅសិក្សាមួយចំនួនតូច សាកល្បងតាមយោបល់មួយចំនួនសម្រាប់ការរៀនសូត្រនៅផ្ទះ។

# អ្វីដែលកូនរបស់លោកអ្នកគួរដឹង និងអាចធ្វើបាននៅក្នុងមុខវិជ្ជាសិល្បៈភាសាអង់គ្លេស

## ភាសា

- ❑ ប្រមូលព័ត៌មានពីការពិភាក្សាក្រុម និងការសម្ភាសដើម្បីប្រើប្រាស់ក្នុងរបាយការណ៍។ សម្រេចថាតើព័ត៌មានណាដែលមានសារៈសំខាន់ និងប្រើប្រាស់វាដើម្បីគាំទ្រចំណុចទាំងឡាយដែលបានបង្កើតនៅក្នុងរបាយការណ៍។
- ❑ ប្រើប្រាស់ព័ត៌មានដែលប្រមូលបានពីការពិភាក្សាក្រុម និងការសម្ភាស ក្នុងរបាយការណ៍។ ឧទាហរណ៍ – ជាផ្នែកនៃមេរៀន ស្តីពីអន្តោប្រវេសន៍ចំពោះប្រទេសនេះ សិស្សបង្កើតសំណួរដើម្បីសួរអ្នកជិតខាង ឬសមាជិកគ្រួសារ និងប្រើប្រាស់ព័ត៌មាននេះនៅក្នុងរបាយការណ៍។

## អំណាន និងអក្សរសិល្ប៍

- ទទួលស្គាល់វិធីដែលសំណេរត្រូវរៀបចំឡើង និងទឡ្ហីករណ៍ត្រូវគេប្រើដើម្បីសម្តែងទស្សនៈគាំទ្រ និងជំទាស់បញ្ហាមួយ។
- កំណត់ និងវិភាគធាតុនៃកាលអាកាស តួអង្គនីយកម្ម លំដាប់ព្រឹត្តិការណ៍ និងទំនាស់នៅក្នុងអក្សរសិល្ប៍។

## សំណេរ

- ❑ រៀបចំព័ត៌មានអំពីប្រធានបទទៅជាកថាខណ្ឌសមហេតុផល។ កថាខណ្ឌគួរតែមាន គំនិតសំខាន់ សេចក្តីលម្អិតគាំទ្រគំនិតសំខាន់គាំទ្រគ្រប់គ្រាន់ និងល្បះបញ្ចប់។
- ❑ ប្រើប្រាស់បច្ចេកទេសសំណេរដែលមិនគោរពតាមលំដាប់កាលប្បវត្តិ – ប្រើប្រាស់ព្រឹត្តិការណ៍ដើម ដើម្បីដាក់ឆាកពីអតីតកាលទៅជាសាច់រឿង។
- ❑ រំលឹកសំណេរដើម្បីកែលម្អការរៀបចំ និងជម្រើសពាក្យ។



# វិធីជួយជំរុញការសិក្សា ELA នៅផ្ទះ

- ❑ សុំឲ្យកូនអានអត្ថបទជ្រើសរើសចេញពីសៀវភៅ ឬអ្នកនិពន្ធដែលកូនចូលចិត្តជាងគេ។ សួរសំណួរដែលជំរុញការគិត និងរៀនសូត្រ ដូចជា "ហេតុអ្វីបានជាគាត់ជាអ្នកនិពន្ធដែលកូនចូលចិត្តជាងគេ?" "តើស្នាដៃអ្វីខ្លះទៀតរបស់អ្នកនិពន្ធរូបនេះដែលកូនបានអាន?" "តើអ្វីជាសាររបស់អ្នកនិពន្ធរូបនេះ?"
- ❑ ចែករំលែក និងពិភាក្សាអំពីប្រលោមលោកយុវជនវ័យក្មេង ជាមួយកូនលោកអ្នក។ សូមសួរសំណួរបើក ដូចជា "តើកូនគិតយ៉ាងណាអំពី _____?" "តើកូនមានគំនិតយ៉ាងម៉េចអំពី _____?" តើនៅពេលណា កូនដោះស្រាយ អ្វីដែលអាចកើតឡើងចំពោះ _____?"
- ❑ ជំរុញកូនលោកអ្នកឲ្យប្រើប្រាស់អំណានដើម្បីប្រមូលព័ត៌មានដើម្បីរៀបចំផែនការធ្វើដំណើរគ្រួសារ ឬសកម្មភាព ឬដើម្បីរៀនសូត្រថែមទៀតអំពីមុខវិជ្ជាមួយដែលកូនរបស់លោកអ្នកចាប់អារម្មណ៍។ ជជែកអំពីអ្វីដែលកូនបានរៀន និងអំពីបញ្ហាថាតើវានឹងមានសារៈប្រយោជន៍ដូចម្តេច។
- ❑ ចូលមើលសារមន្ទីរក្នុងមូលដ្ឋាន ដូចជាសារមន្ទីរសិល្បៈ Portland (portlandartmuseum.org), សារមន្ទីរសិល្បៈ និងវប្បធម៌អាហ្វ្រិក (museumafricanculture.org) ឬចូលមើលវិចិត្រសាល Lewis របស់បណ្ណាល័យសាធារណៈ Portland (portlandlibrary.com)។

## កំណត់ចំណាំ:

___

___

___

___

___

___

___

___

___

___

សូមទាក់ទងជាមួយលោកគ្រូអ្នកគ្រូរបស់កូនលោកអ្នក និងសាកសួរពីធនធានសិក្សានៅផ្ទះដែលពាក់ព័ន្ធជាមួយកម្មវិធីអំណាន និងសំណេរជាក់លាក់របស់សាលារៀន។

# អ្វីដែលកូនរបស់លោកអ្នកគួរដឹងនិងអាចធ្វើបាននៅក្នុងមុខវិជ្ជាគណិតវិទ្យា

- ❑ ធ្វើការប្រៀបធៀបគ្នាដោយប្រើផលធៀប ប្រភាគ ទសភាគ អត្រា អត្រាឯកតា និងភាគរយ។ ឧទាហរណ៍ – ស្វែងរកថាតើរូបមន្តផ្សេងៗដែលប្រើទឹក និងកំហាប់ទឹកផ្លែឈើ បង្កើតទឹកផ្លែឈើដែលមានរសជាតិជាង ឬមិនសូវមានរសជាតិ តាមរបៀបណា។
- ❑ បូក ដក គុណ និងចែកចំនួនគត់(ឡាំរ៉ុទីប)។ ឧទាហរណ៍ – 5 + (-3) = 2 និង 5 x (-3) = -15
- ❑ យល់ពីទំនាក់ទំនងលីនេអ៊ែរ – អត្រាថេរនៃបម្រែបម្រួលរវាងអថេរពីរ។ ឧទាហរណ៍ – កម្ពស់គំនរក្រដាស់កើនឡើងជាប្រចាំ ដោយសារតែគេបន្ថែមចំណែកក្រដាសទៅលើគំនរក្រដាសនោះ។
- ❑ ស្គាល់ទំនាក់ទំនងលីនេអ៊ែរនៅក្នុងចំណោទពាក្យ តារាង ក្រាហ្វ ឬសមីការ។
- ❑ ដោះស្រាយ និងសរសេរសមីការលីនេអ៊ែរ។
- ❑ ប្រើប្រាស់លក្ខណៈរូបភាពស្រដៀងគ្នាដែលមានរូបរាងដូចគ្នា ប៉ុន្តែមានទំហំខុសគ្នា ដើម្បីស្វែងរកការបង្រួម និងពង្រីក។
- ❑ បង្កើតវិធីសម្រាប់វាស់ផ្ទៃក្រឡា និងកម្រិតនៃរូបភាពដែលមានវិមាត្របី។ ឧទាហរណ៍ – រកសម្ភារៈដែលចាំបាច់សម្រាប់ខ្ចប់ប្រអប់មួយ និងចន្លោះសម្រាប់ទុកប្រអប់នោះ។
- ❑ រកប្រូបាប៊ីលីតេតាមការធ្វើពិសោធន៍ និងប្រមូលព័ត៌មាន។



# ការសិក្សាគណិតវិទ្យានៅផ្ទះ

- ❑ ឲ្យកូនលោកអ្នកវាស់វែងប្រវែងជ្រុងបន្ទប់នៅក្នុងផ្ទះ ហើយបន្ទាប់មករកបរិមាត្រ និងផ្ទៃក្រឡារបស់បន្ទប់នោះ។
- ❑ ស្វែងរកឱកាសនៅក្នុងជីវភាពប្រចាំថ្ងៃដើម្បីប្រើប្រាស់លេខធំៗជាមួយកូនលោកអ្នក។ ឧទាហរណ៍ – ប្រៀបធៀបតម្លៃម៉ូដែលរថយន្តផ្សេងៗដែលគេផ្សាយពាណិជ្ជកម្ម ឬប្រៀបធៀបប្រជាពលរដ្ឋរស់នៅ Portland ជាមួយប្រជាពលរដ្ឋក្នុងទីក្រុងដែលសាច់ញ្ញាតិ ឬមិត្តភក្តិរស់នៅ។
- ❑ រកប្រភាគ និងភាគរយនៅក្នុងការលក់នៅតាមហាងក្នុងមូលដ្ឋាន។ ឲ្យកូនរបស់លោកអ្នកគណនារកមើលថាតើលោកអ្នកនឹងសន្សំបានប្រាក់ប៉ុន្មានលើវត្ថុដាក់លក់។
- ❑ ធ្វើប្រមាណវិធីបូក និងដកប្រាក់ដូល្លារ និងសេនដើម្បីប្រើប្រាស់ចំនួនទសភាគនៅក្នុងជីវភាពប្រចាំថ្ងៃ។ ឲ្យកូនលោកអ្នកប៉ាន់ប្រមាណជាមុននូវតម្លៃនៃវត្ថុបី ឬច្រើន ហើយបន្ទាប់មកគណនារកចំនួនសរុប។

## កំណត់ចំណាំ:

សូមទាក់ទងជាមួយលោកគ្រូអ្នកគ្រូរបស់កូនលោកអ្នក និងសាកសួរពីធនធានសិក្សានៅផ្ទះដែលពាក់ព័ន្ធជាមួយកម្មវិធីគណិតវិទ្យាជាក់លាក់របស់សាលារៀន។with your school's specific math program.

PORTLAND PUBLIC SCHOOLS
Academics Office
353 Cumberland Avenue
Portland, Maine 04101
207.874.8100
portlandschools.org

L.L.Bean

សេចក្តីណែនាំអំពីការរិក្សាម្រោប់ម្រួសាររិសេស ៖ អាចស្នើសៅបា
សៅសម្រកាមជាំួយដ៏ថ្លៃថ្លៃរប់ម្រក្មុមហ៊ុ L.L.Bean.

កូនសៀវភៅផ្សព្វផ្សាយនេះត្រូវបានបោះពុម្ពដោយសាលារៀន Portland។
ខ្លឹមសារត្រូវបានប្រើប្រាស់ និងកែប្រែដោយមានការអនុញ្ញាតពីសាលារៀន
សាធារណ: Boston។ ខ្លឹមសារបន្ថែមគឺផ្អែកលើស្នាដៃរបស់បណ្ឌិត
Anthony L. Moore។

Created Fall 2016

Khmer